# ពត៌មានស្តីអំពីជម្ងឺមហារីកប្រូស្តេត (Prostate Cancer)

**តើជម្ងឺមហារីកក្រពេញប្រូស្តេតគឺជាអ្វី?**

ប្រូស្តេតមានទំហំប៉ុនផ្លែវ៉ាលណាត់ (walnut) មានតែបុរសទេដែលមាន។ ហើយវានៅខាងក្រោមតម្រងនោម និងខាងមុខចុងពោះវៀនធំ។ បុរសជនជាតិអាស៊ី និងបុរសមកពីកោះនៅសមុទ្រប៉ាស៊ីហ្វិកជាច្រើន តែងតែកើតជម្ងឺមហារីកប្រូស្តេត។ មានការពិនិត្យធ្វើតែស្តមួយចំនួន ដែលអាចជួយឲ្យរកឃើញជម្ងឺមហារីកប្រូស្តេត នៅពេលដែលវាទើបតែកើតមានថ្មីៗ។ ប៉ុន្តែយើងក៏មិនបានដឹងឲ្យពិតប្រាកដថា៖ ការធ្វើរោគវិនិច្ឆ័យរកឃើញជម្ងឺនៅពេលដែលវាទើបតែចាប់ផ្តើមកើតមាន អាចជួយបង្កើននូវអត្រាឲ្យរួចផុតពីការស្លាប់ដោយសារជម្ងឺនេះទេ។ អំពីសេចក្តីសំរេចចិត្ត ក្នុងការធ្វើតែស្តពិនិត្យជម្ងឺនេះ វាអាស្រ័យទៅលើខ្លួនលោកអ្នកផ្ទាល់ និងគ្រូពេទ្យរបស់លោកអ្នក។

**តើនរណាខ្លះ អាចរងគ្រោះដោយសារជម្ងឺនេះ?**

- បុរសទាំងអស់ដែលមានអាយុច្រើនជាង ៥០ឆ្នាំ
- បុរសដែលទទួលទានអាហារដែលមានជាតិខ្លាញ់ច្រើន
- បុរសដែលមានប្រវត្តិគ្រួសារធ្លាប់កើតជម្ងឺមហារីកប្រូស្តេត

**ការណែនាំសំរាប់ការពិនិត្យ:**

- នៅពេលដែលលោកអ្នកមានអាយុ ៥០ឆ្នាំ ចូរពិភាក្សាជាមួយគ្រូពេទ្យរបស់លោកអំពីការយកឈាមពីប្រូស្តេតទៅពិនិត្យ និងការពិនិត្យប្រូស្តេតដោយប្រើឌីហ្ស៊ីតាល់ (Digital) ស៊កចូលតាមចុងពោះវៀនធំ។
- កត្តាដែលគួរយកមកវិនិច្ឆ័យ ដើម្បីសម្រេចកំណត់ការពិនិត្យប្រចាំឆ្នាំមាន : សុខភាពរបស់លោកអ្នកទូទៅមកដល់សព្វថ្ងៃនេះ និងអាយុកាលមធ្យម។
- បុរសដែលយល់ថា ខ្លួនអាចមានគ្រោះថ្នាក់ដោយសារជម្ងឺនេះ (ដូចជាមានញាតិសន្តានធ្លាប់កើតជម្ងឺមហារីកប្រូស្តេត) ត្រូវពិភាក្សាជាមួយគ្រូពេទ្យរបស់លោកអ្នកពីការធ្វើតែស្តបែបនេះឲ្យបានឆាប់។

**រោគសញ្ញានិងអាការរោគ**

- ជម្ងឺមហារីកប្រូស្តេតនេះ ភាគច្រើន មិនមានរោគសញ្ញាអ្វីទេនៅពេលដែលទើបតែកើតមានថ្មីៗ។ នៅពេលដែលបុរសមានអាយុកាន់តែច្រើន ប្រូស្តេតរបស់ពួកគេច្រើនតែរីកធំ ដែលមិនមែនជាជម្ងឺមហារីក។ ទោះជាដូច្នេះក្តី បុរសណាមានអាការរោគអ្វីមួយដូចដែលបានរាយនៅខាងក្រោមនេះ ត្រូវទៅជួបគ្រូពេទ្យ ដើម្បីពិនិត្យឲ្យដឹងច្បាស់ថា តើនោះបណ្តាលមក ពីជម្ងឺមហារីកប្រូស្តេតឬទេ?

- បទដើងតូចញឹកញាប់ ជាពិសេសនៅពេលយប់
- មានការលំបាកក្នុងការចាប់ផ្តើមបត់ជើងតូច ឬទ្រាំទប់បត់ជើងតូច
- នៅពេលបត់ជើងតូច ទឹកនោមហូរចេញរអាក់រអួល
- មានការឈឺផ្សារនៅពេលបត់ជើងតូច ឬនៅពេលបញ្ចេញទឹកកាម
- មានឈាមលាយក្នុងទឹកនោម ឬទឹកកាម
- ឈឺ ឬមានភាពចុករោយនៅផ្នែកខាងក្រោមនៃខ្នង ចង្កេះ ឬភ្លៅខាងលើ

## អំពីការធ្វើតែស្តពិនិត្យជម្ងឺមហារីកប្រស្តេត

ការយកឈាមទៅពិនិត្យសារធាតុ PSA (Prostate-specific Antigen) - PSA ជាសារធាតុម្យ៉ាងនៅក្នុងខ្លួនយើងជួយការពារនិងទប់ទល់រោគាផ្សេងៗ

- គ្រូពេទ្យនិងបូមឈាមយកទៅវាស់មើលកំរិតសារធាតុ PSA
- កំរិតសារធាតុ PSA ល្អធម្មតាគឺ ត្រឹម 4.0 ng/ml. ឬក៏តិចជាងនេះ។
- បើកំរិតសារធាតុ PSA របស់លោកកើនច្រើនជាងកំរិតធម្មតាបន្តិចបន្តួច វាមិនមែនមានន័យថាលោកមានជម្ងឺមហារីកប្រស្តេតទេ វាអាចមានហេតុភេទផ្សេងៗទៀតដែលធ្វើឲ្យកំរិត PSA របស់លោកកើនឡើងខ្ពស់ជាង 4.0។ គ្រូពេទ្យរបស់លោកអាចណែនាំឲ្យលោកធ្វើតែស្តម្តងទៀត ដើម្បីពិនិត្យឲ្យដឹងច្បាស់ថាកំរិតវានៅតែខ្ពស់ជាងធម្មតា។ គ្រូពេទ្យអាចណែនាំឲ្យធ្វើតែស្តផ្សេងថែមទៀត ដើម្បីពិនិត្យមើលខ្លាចមានជម្ងឺមហារីក។

ការពិនិត្យតាមចុងពោះវៀនធំដោយប្រើឱហ្ស៊ុតាល់ (Digital Rectal Exam – DRE)

- នៅក្នុងកំឡុងពេលធ្វើការពិនិត្យនេះ គ្រូពេទ្យនឹងសកម្រាមដៃដែលបានពាក់ស្រោមនិងលាបប្រេងចូលតាមចុងពោះវៀនធំ ដើម្បីស្ទាបប្រស្តេតរកមើលកន្លែងដែលរឹងខុសពីប្រក្រតី ដែលអាចជាជម្ងឺមហារីក។ ប្រស្តេតនៅជិតចុងពោះវៀនធំ ហើយជម្ងឺមហារីកភាគច្រើន ចាប់ផ្តើមកើតពីកន្លែងនេះ ដែលធ្វើឲ្យយើងអាចពិនិត្យបានដោយប្រើវិធីពិនិត្យបែបនេះ។

- ការធ្វើតែស្តបែប DRE មានប្រសិទ្ធភាពច្រើននៅពេលប្រើរួមជាមួយនឹងការធ្វើតែស្តបែប PSA។

ការធ្វើតែស្តបែបផ្សេងៗទៀត:

- ការឆ្លុះពិនិត្យតាមចុងពោះវៀនធំដោយប្រើអុលត្រាសោន : គ្រូពេទ្យនឹងសកបំពង់ដ៏ស្តើងតូចមួយចូលទៅតាមចុងពោះវៀនធំ ដែលមានគ្រឿងបញ្ជូនភ្ជាប់នៅចុងម្ខាងទៀត ហើយ

ធ្វើឲ្យគ្រូពេទ្យពិនិត្យមើលប្រស្តេតពីក្នុងចុងពោះវៀនធំ។ វិធីនេះ ជួយធ្វើឲ្យគ្រូពេទ្យមើលឃើញអ្វីៗ ដែលខុសពីប្រក្រតី ដែលអាចនឹងកើតមាននៅក្នុងសរីរាង្គនេះ។

**ឯកសារជំនួយ:**

- Cancer Infromation Service (800) 4-CANCER, ជាកម្មវិធីរបស់វិជ្ជាស្ថានជាតិផ្នែកជម្ងឺមហារីក http://cancernet.nci.nih.gov
- American Cancer Society (800) ACS-2345